NSW HEALTH
July 2005
[DOH-7620]

**KHMER**

# សេចក្តីណែនាំសំរាប់ការយកកំហាកដើម្បីពិនិត្យមើលរបេង (TB)
# Instructions for Collecting Sputum for Tuberculosis (TB)

មានការស្នើសុំឲ្យលោកអ្នកយកកំហាក(ស្លេស្ម)នៅពេលព្រឹកព្រលឹម ៣ ដង។ ដើម្បីជួយលោកអ្នក ក្នុងការយកកំហាកទាំងនេះ យើងខ្ញុំបានផ្តល់ឲ្យលោកអ្នកនូវកូនកែវ៣ សំរាប់ដាក់កំហាក និងថង់ប្លាស្ទិកមួយ។ កែវទាំងនោះមាន ផ្លាកដែលមានឈ្មោះរបស់លោកអ្នក ហើយមានបិទលេខ "1", លេខ "2" និងលេខ "3" សំរាប់ពេល ៣ ថ្ងៃ ជាប់ៗគ្នា។ *សូមប្រុងប្រយ័ត្ន កុំឲ្យមានការប៉ះពាល់ផ្នែកខាងក្នុងកែវឲ្យសោះ។*

**កំណត់ចំណាំ:** ជាការសំខាន់ចាំបាច់ដែលលោកផ្តល់កំហាក/ស្លេស្ម ចេញពីសួតរបស់លោកអ្នក ពោលគឺមិនមែនទឹកមាត់ (វត្ថុធាតុរាវនៅក្នុងមាត់) ទេ សំរាប់ការធ្វើតេស្ត។

**បើសិនជាលោកអ្នកមានបញ្ហាក្នុងការបញ្ចេញកំហាក** សូមបើកក្បាលម៉ាស៊ីនទឹកនៅក្នុងបន្ទប់ទឹក រហូតទាល់តែបន្ទប់ទាំងមូលឡើងចំហាយ។ (សូមប្រយ័ត្នប្រយែងកុំឲ្យមានទឹកក្តៅហូរហៀរលោក)។ សូមបិទទ្វារ ហើយអង្គុយនៅក្នុងបន្ទប់មានចំហាយនេះ ពី៥ ទៅ១០ នាទី ហើយសាកល្បងធ្វើម្តងទៀត។ បើមិនដូច្នោះទេ លោកអ្នកអាចសាកល្បងដូតទឹកផ្កាឈូក ឬក៏ទឹកក្នុងអាងក្តៅឧណ្ហៗ មុននឹងក្អកយកកំហាក។ សូមដកដង្ហើមឲ្យបានខ្លាំងៗ ដោយសង្កត់យ៉ាងខ្លាំងទៅលើចំហៀងដើមទ្រូងទាំងសងខាងរបស់លោកអ្នកព្រមគ្នា ហើយការប្រឹងក្អកយ៉ាងខ្លាំងអាចជួយបញ្ចេញនូវកំហាក។

**ការណែនាំ:**

១. នៅពេលដែលលោកអ្នកភ្ញាក់ពីដំណេកនៅពេលព្រឹក និង **មុនពេលដែលលោកអ្នកទទួលទានទឹក ឬក៏អ្វីផ្សេងទៀត ឬក៏សំអាតធ្មេញ** សូមយកកំហាកដាក់ទៅក្នុងកែវដែលមានផ្លាកលេខ "1" សិន ។ (សូមឆែកមើលឲ្យច្បាស់ថា លោកអ្នកមិនមែនស្តោះចេញមកតែទឹកមាត់នោះទេ)។

២. សូមសរសេរថ្ងៃខែនិងម៉ោងលើកែវដែលមានផ្លាកលេខ "1" ស្តីអំពីការដាក់កំហាកនេះទៅក្នុងកែវនោះ។

៣. **សូមមួលបិទគម្របកែវឲ្យបានជាប់ល្អ ដើម្បីចៀសវាងកុំឲ្យមានការកំពប់ហូរចេញ។**

៤. សូមដាក់កែវនោះទៅក្នុងថង់ប្លាស្ទិកដែលផ្តល់ជូនស្រាប់នោះ។

៥. សូមដាក់ថង់ប្លាស្ទិកដែលមានកែវនោះ ទៅក្នុងទូទឹកកក **មិនមែនទូក្លាសេទេ។**

៦. សូមធ្វើតាមវិធានការណែនាំពីលេខ ១ ទៅដល់លេខ ៥ សំរាប់ ព្រឹកទី ២ និងព្រឹកទី ៣ ជាបន្តបន្ទាប់ ដោយប្រើកែវ (ដែលមានផ្លាកលេខ “2” និង “3” )។

៧. សូមប្រគល់កែវដាក់កំហាកទាំងនោះ ទៅមន្ទីរពិនិត្យសួត/របេង ឬក៏នាយកដ្ឋានពិសោធន៍មើលរោគ (កន្លែងណាមួយដែលគេណែនាំឲ្យយកទៅ) **ឲ្យបានឆាប់ទៅតាមលទ្ធភាព** ក្រោយពីបានយកកំហាកចុងក្រោយរួច។ សូមទុកដាក់កែវកំហាកទាំងនោះ នៅក្នុងកន្លែងត្រជាក់ ហើយកុំឲ្យត្រូវពន្លឺថ្ងៃ

របបួតដល់ពេលយកទៅមន្ទីរពេទ្យ។

**កំណត់ចំណាំ:** គេអាចត្រូវការពេលដល់ទៅ ៣ ថ្ងៃ ជាថ្ងៃធ្វើការ ដើម្បីទាញយកលទ្ធផលដំបូង ហើយចំពោះលទ្ធផលបណ្ដុះចុងក្រោយអាចត្រូវការពេលពី ៦ ទៅ ៨ អាទិត្យ។ គិលានុបដ្ឋាកនៅមន្ទីរពិនិត្យសួតនឹងជំរាបឲ្យលោកអ្នកដឹង អំពីភាពមិនប្រក្រតីទាំងឡាយណា។

*បើលោកអ្នកមានសំណួរអ្វីស្ដីអំពីការយកកំហាកដើម្បីឲ្យពេទ្យពិនិត្យមើល សូមទាក់ទងមន្ទីរពិនិត្យសួតតាមទូរស័ព្ទលេខ:*

សូមអរគុណ